សូមហៅទូរស័ព្ទមកកាន់កម្មវិធី
តាមលេខដែលមិនបាច់បង់ប្រាក់
ដើម្បីបានដឹងថា អ្នកមានលក្ខណៈ
សម្បត្តិអាចទទួលការពិនិត្យបានដែរឬទេ៖

**1-800-511-2300**

ពីថ្ងៃច័ន្ទ - ថ្ងៃសុក្រ ម៉ោង8:30នាទីព្រឹក-5ល្ងាច

ទូរស័ព្ទភាសាអង់គ្លេស ចំពោះ
ភាសាអេស្បាញ (សូមចុចលេខ 2) ភាសាចិន
(សូមចុចលេខ 3) ភាសាវៀតណាម
(សូមចុចលេខ 5) ភាសាកូរ៉េ (សូមចុចលេខ 6)
និងភាសាចិនកន្តាំង (សូមចុចលេខ 7) ។




ដើម្បីបានទទួលការពិនិត្យទាំងអស់នេះ
ដោយមិនបាច់បង់ថ្លៃ ដើម្បីរកមើលមហារីកដោះ
និងមហារីកកស្បូន អ្នកត្រូវតែ៖

- ជាអ្នករស់នៅក្នុងរដ្ឋកាលីហ្វ័រនីញ៉ា
- មានអាយុទៅតាមភាពតម្រូវ
- មិនមាន ឬមានការធានារ៉ាប់រងសុខភាពតិចតួច
- មានការធានារ៉ាប់រងសុខភាព ដែលត្រូវចំណាយរួម ឬការចំណាយមួយចំនួនដែលត្រូវកាត់ឲ្យអ្នកចេញ តែអ្នកគ្មានលទ្ធភាព
- មានប្រាក់ចំណូលក្នុងគ្រួសារទាប



បើអាចរកឃើញជម្ងឺមហារីកដោះបានទាន់ពេលវេលា មានឱកាសខ្ពស់ក្នុងការព្យាបាលឲ្យជាសះស្បើយ ។



ពេលអ្នកមានលក្ខណៈសម្បត្តិអាចបានទទួលជំនួយពីកម្មវិធីផ្តល់ជំនួយវេជ្ជសាស្ត្រដល់ស្ត្រីគ្រប់រូប អ្នកនឹងត្រូវបានគេបញ្ជូនទៅកាន់គ្លីនិចដែលចូលរួមក្នុងកម្មវិធីដែលនៅក្បែរអ្នក ។

Every Woman Counts

1-800-511-2300

http://dhcs.ca.gov/EveryWomanCounts

តាមការស្នើសុំ ឯកសារនេះអាចផ្តល់ជូនអ្នកដោយភាសាផ្សេងទៀត ។ ដើម្បីបានទទួលឯកសារនេះដោយភាសាផ្សេងទៀត សូមទំនាក់ទំនងមកកាន់យើងខ្ញុំតាមរយៈអាសយដ្ឋាន ៖

Every Woman Counts
PO Box 997417, MS 4600
Sacramento, CA 95899-7377
លេខទូរស័ព្ទ 916-449-5300
លេខបន្តរបស់រដ្ឋកាលីហ្វ័រនីញ៉ា 711/1-800-735-2929

ថវិកាជ្រោមជ្រែងចំពោះថ្លៃឯកសារនេះបានទទួលពីកម្មវិធីផ្តល់ជំនួយវេជ្ជសាស្ត្រគ្រប់រូប នៃនាយកដ្ឋានសេវាកម្មថែទាំសុខភាពរបស់រដ្ឋកាលីហ្វ័រនីញ៉ា ។

6/2013

# កម្មវិធី ជំនួយវេជ្ជសាស្ត្រដល់ស្ត្រីគ្រប់រូប របស់រដ្ឋកាលីហ្វ័រនីញ៉ា











ការពិនិត្យដោះ ការថតកាំរស្មីអ៊ិចលក្ខណៈពីរទិស និងការធ្វើតេស្ត Pap រកមើលជម្ងឺមហារីកដោះ ដោយឥតគិតថ្លៃ

## តើអ្វីជាកម្មវិធីផ្តល់ជំនួយវេជ្ជសាស្ត្រដល់ស្ត្រីគ្រប់រូប?

កម្មវិធីផ្តល់ជំនួយវេជ្ជសាស្ត្រដល់ស្ត្រីគ្រប់រូប មានផ្តល់ជូននូវការពិនិត្យរកមើលជម្ងឺមហារីកដោះ និងមហារីកកស្បូន និងសេវាកម្មតាមដានក្រោយពិនិត្យដល់ស្ត្រីដោយឥតគិតថ្លៃ ។ ការពិនិត្យនេះ មានរួមទាំងការពិនិត្យដោះ ការថតកាំរស្មីអិចសខុមៅលក្ខណៈពីរទិសនិងការពិនិត្យ Pap ក៏ដូចជាការពិនិត្យដទៃទៀតតាមភាពចាំបាច់ ដល់ស្ត្រីគ្រប់រូបរស់នៅក្នុងរដ្ឋបកាលីហ្វ័រនីញ៉ាដែលមានលក្ខណៈសម្បត្តិបានទទួលជំនួយ ។

ពេលដែលស្ត្រីកាន់តែឈានចូលវ័យចំណាស់ ជាពិសេសក្រោយពីអាយុ 50 ឆ្នាំ ឱកាសក្នុងការកើតជម្ងឺមហារីកដោះ និងមហារីកកស្បូន មានការកើនឡើង ។ ស្ត្រីទាំងនោះគួរបានទទួលការពិនិត្យរកមើលជម្ងឺមហារីកដោះ និងមហារីកកស្បូនដោយទៀងទាត់ ដែលធ្វើឡើងដោយគ្រូពេទ្យ ។

កម្មវិធីផ្តល់ជំនួយវេជ្ជសាស្ត្រដល់ស្ត្រីគ្រប់រូប មានផ្តល់ជូនសេវាកម្មមួយចំនួនដោយឥតគិតថ្លៃ ៖

- ការពិនិត្យដោះ និងការថតកាំរស្មីសខុមៅលក្ខណៈពីរទិសដល់ស្ត្រីដែលមានអាយុ 40 ឆ្នាំ និងចាស់ជាងនេះ ដែលមានលក្ខណៈសម្បត្តិអាចបានទទួលជំនួយ
- ការពិនិត្យ Pap ដល់ស្ត្រីដែលមានអាយុ 21ឆ្នាំ និងចាស់ជាងនេះ ដែលមានលក្ខណៈសម្បត្តិអាចបានទទួលជំនួយ
- ការធ្វើតេស្ត HPV ដល់ស្ត្រីដែលមានអាយុ 30 ឆ្នាំ និងចាស់ជាងនេះដែលមានលក្ខណៈសម្បត្តិអាចបានទទួលជំនួយ
- ធ្វើតេស្តតាមដានក្រោយការពិនិត្យ បើមានភាពចាំបាច់

**ជម្ងឺមហារីកដោះ:
ជាជម្ងឺដែលសាមញ្ញបំផុត ក្នុងចំណោមជម្ងឺដែលកើតចំពោះស្ត្រីនៅរដ្ឋបកាលីហ្វ័រនីញ៉ា ។**

## ហេតុអ្វីបានជាអ្នកគួរទទួលការពិនិត្យរកមើលជម្ងឺមហារីកដោះ?

- ការពិនិត្យដោះ អាចជួយឲ្យគ្រូពេទ្យបានឃើញ និងបានដឹងអំពីការប្រែប្រួលណាមួយដែលកើតឡើងចំពោះដោះរបស់អ្នក ។
- ការថតកាំរស្មីអិចសខុមៅលក្ខណៈពីរទិស អាចជួយឲ្យគ្រូពេទ្យរកឃើញជម្ងឺមហារីកដោះ ដែលវានៅតូចនៅឡើយ ដោយមិនអាចធ្វើឲ្យអ្នក ឬគ្រូពេទ្យរបស់អ្នកអាចដឹងបាន ។
- ពេលគ្រូពេទ្យអាចរកឃើញជម្ងឺមហារីកដោះបានទាន់ពេលវេលា វាមានភាពងាយស្រួលជាងក្នុងការព្យាបាល ។



## តើអ្នកគួរបានទទួលការពិនិត្យរកមើលជម្ងឺមហារីកដោះញឹកញាប់ប៉ុណ្ណា?

ការបានដឹងអំពីស្ថានភាពដោះរបស់អ្នក គឺជារឿងសំខាន់ សម្រាប់ការរកឃើញជម្ងឺមហារីកដោះបានទាន់ពេលវេលា ។ ចូរពិភាក្សាជាមួយគ្រូពេទ្យរបស់អ្នក អំពីពេល និងភាពញឹកញាប់ដែលអ្នកគួរពិនិត្យរកមើលជម្ងឺមហារីកដោះ ។

**សម្រាប់ព័ត៌មានបន្ថែម សូមហៅទូរស័ព្ទដោយមិនបាច់បង់ប្រាក់មកកាន់យើងខ្ញុំ តាមរយៈលេខ 1-800-511-2300**

**ជម្ងឺមហារីកកស្បូន
គឺស្ទើរតែអាចបង្ការបាន 100%
ដោយការពិនិត្យ Pap ឲ្យបានទៀងទាត់ ។**

## ហេតុអ្វីបានជាអ្នកគួរពិនិត្យរកមើលជម្ងឺមហារីកកស្បូន?

ការពិនិត្យរកមើលជម្ងឺមហារីកកស្បូន គឺជាការពិនិត្យ Pap និងពិនិត្យ HPV ។

- ការពិនិត្យ Pap គឺជាការរកមើលអំពីការប្រែប្រួលកោសិកានៅក្នុងកស្បូន ដែលការប្រែប្រួលនេះអាចនាំឲ្យកើតជម្ងឺមហារីក ។
- ការធ្វើតេស្ត HPV គឺជាការរកមើលវីរុសដែលអាចបង្កឲ្យមានការប្រែប្រួលកោសិកានៅក្នុងកស្បូន ។
- ការព្យាបាលការប្រែប្រួលកោសិកាទាំងនេះ អាចជួយបង្ការជម្ងឺមហារីកកស្បូនបាន ។

## តើអ្នកគួរទទួលការពិនិត្យរកមើលជម្ងឺមហារីកកស្បូនញឹកញាប់ប៉ុណ្ណា?

កម្មវិធីផ្តល់ជំនួយវេជ្ជសាស្ត្រដល់ស្ត្រីគ្រប់រូប មានផ្តល់ជូននូវការពិនិត្យ Pap ដោយឥតគិតថ្លៃ ចំពោះស្ត្រីដែលមានអាយុ 21 និងចាស់ជាងនេះ ដែលមានលក្ខណៈសម្បត្តិអាចបានទទួលជំនួយ ហើយបន្ទាប់មកបានទទួលការពិនិត្យដោយឥតគិតថ្លៃរៀងរាល់បីឆ្នាំម្តង បើលទ្ធផលការពិនិត្យដំបូងបង្ហាញថាមានភាពធម្មតា ។

ស្ត្រីដែលមានអាយុ 30 ឬចាស់ជាងនេះ អាចជ្រើសយកការធ្វើតេស្ត Pap ជាមួយនឹងការធ្វើតេស្ត HPV បើនាងគួរការពិនិត្យលើកក្រោយបន្ទាប់ពី 5 ឆ្នាំ ។ បើលទ្ធផលការពិនិត្យដំបូងទាំងពីរបង្ហាញថាមានភាពធម្មតា ឱកាសក្នុងការកើតជម្ងឺមហារីកកស្បូនក្នុងរវាងពីរបីឆ្នាំខាងមុខ មានភាពទាបបំផុត ។

